

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# ទស្សនវិស័យមុខរបរ និងការងារ

## តម្រូវការជំនាញ និងការងារសម្រាប់យុវជន



លេខ៣ ឆមាសទី១ ឆ្នាំ២០២៥

# **អារម្ភកថា**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍទីផ្សារការងារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។ ការដាក់ចេញ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម មានគោលបំណងបង្កើត រក្សា និងបង្កើនការងារសម្រាប់ប្រជាជនគ្រប់រូប ជាពិសេសយុវជន និងកម្មករនិយោជិតទាំងក្នុងនិងក្រៅប្រព័ន្ធ។ ក្នុងនោះ ការធ្វើបច្ចុប្បន្នភាពព័ត៌មានទីផ្សារការងារ ដែលគ្រប់ជ្រុងជ្រោយ គឺជាកត្តាចាំបាច់ក្នុងការសម្រេចគោលដៅនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាប់ផ្តើមរៀបចំ និងផ្សព្វផ្សាយនូវព្រឹត្តិបត្រព័ត៌មាន **«ទស្សនវិស័យមុខរបរ និងការងារ»** សម្រាប់ឆមាសទី១ និងទី២ ក្នុងឆ្នាំ២០២៤។ សម្រាប់ឆ្នាំ២០២៥ នេះ ក្រសួងបន្តរៀបចំ និងបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានទីផ្សារការងារលេខ៣ ស្តីពី **«ទស្សនវិស័យមុខរបរ និងការងារ»** សម្រាប់ឆមាសទី១ ឆ្នាំ២០២៥។ ព្រឹត្តិបត្រនេះគឺជាផែនទីបង្ហាញផ្លូវសម្រាប់ការកំណត់ជំនាញ និងការងារដែលមានតម្រូវការខ្ពស់នៅតាមវិស័យកំពុងរីកចម្រើន ព្រមទាំងដើរតួជាមគ្គុទេសក៍សម្រាប់ការសិក្សា និងការអភិវឌ្ឍអាជីព។

ព័ត៌មានទាំងនេះ មានសារៈសំខាន់ណាស់សម្រាប់សិស្ស និស្សិត ក្នុងការជ្រើសរើសជំនាញសិក្សា និងវិជ្ជាជីវៈឱ្យស្របតាមតម្រូវការទីផ្សារការងារ។ ចំពោះអ្នកស្វែងរកការងារ ព័ត៌មានទាំងនេះនឹងផ្តល់ភាពងាយស្រួលក្នុងការកំណត់ទិសដៅ និងរៀបចំផែនការស្វែងរកការងារប្រកបដោយប្រសិទ្ធភាព។ ចំណែកឯនិយោជក ព័ត៌មានទាំងនេះនឹងបន្ថែមការយល់ដឹងអំពីតម្រូវការជំនាញ និងស្វែងរកបុគ្គលិក ដែលមានសមត្ថភាពសមស្របទៅនឹងតម្រូវការរបស់ខ្លួន។

ដើម្បីបន្តរួមចំណែកដល់ការអភិវឌ្ឍទីផ្សារការងារ និងកាត់បន្ថយគម្លាតជំនាញ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តខិតខំប្រឹងប្រែងក្នុងការប្រមូល និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារឱ្យកាន់តែទាន់សម័យ និងគ្រប់ជ្រុងជ្រោយ។ ក្រសួងសង្ឃឹមយ៉ាងមុតមាំថា ព្រឹត្តិបត្រព័ត៌មាន **«ទស្សនវិស័យមុខរបរ និងការងារ»** នេះ នឹងក្លាយជាឯកសារយោងដ៏មានប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធ ទាំងអ្នករៀបចំគោលនយោបាយ អ្នកផ្តល់ការអប់រំ និងបណ្តុះបណ្តាល អ្នកសិក្សាស្រាវជ្រាវ និងសាធារណជន។

ថ្ងៃ ចន្ទ ៥កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

សម្រាប់ការដាក់ឯកសារយោង៖ អ៊ុំ ច័ន្ទមនោ, ទ្រី សុផល, គី សេរីវុធ, ប៊ុន បូពិត, អ៊ុំ សូម៉ារ៉ា (២០២៥)។
ទស្សនវិស័យមុខរបរ និងការងារ៖ តម្រូវការជំនាញ និងការងារសម្រាប់យុវជន ឆមាសទី១ ឆ្នាំ២០២៥។
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

## មាតិកា


ផ្នែកទី១៖ ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារការងារប្រទេសកម្ពុជា........១

ក. ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា........១

ខ. ស្ថានភាពកម្លាំងពលកម្មកម្ពុជា........៣

គ. ការវិនិយោគផ្ទាល់ពីបរទេស (FDI) និង គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIPs)........៤

ឃ. មុខរបរមានកំណើនលឿនក្នុងឆមាសទី១ ឆ្នាំ២០២៥........៥

ង. មុខរបរថយចុះក្នុងឆមាសទី១ ឆ្នាំ២០២៥........៧

ផ្នែកទី២៖ ការព្យាករនៃតម្រូវការការងារនៅកម្ពុជាក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម........៩

ផ្នែកទី៣៖ តម្រូវការមុខរបរក្នុងទីផ្សារការងារតាមកម្រិតនៃជំនាញ និងមុខតំណែង........២៣

ផ្នែកទី៤៖ ការចាប់យកឱកាសបណ្តុះបណ្តាល ប្រឹក្សាយោបល់ការងារ និងថែទាំសុខភាព........២៥

ក. ឱកាសទទួលបានការបណ្តុះបណ្តាលដោយមិនគិតថ្លៃ និងទទួលបានប្រាក់ខែសមរម្យ........២៥

ខ. ឱកាសទទួលបានការប្រឹក្សាយោបល់ និងឱកាសការងារ........២៦

គ. ឱកាសទទួលបានការពិគ្រោះ និងថែទាំសុខភាព........២៧


# ផ្នែកទី១៖ ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារការងារប្រទេសកម្ពុជា

## ក. ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានព្យាករថានឹងមានកំណើនប្រមាណ ៦,៣% នៅឆ្នាំ២០២៥ ដែលជំរុញដោយវិស័យឧស្សាហកម្ម សេវាកម្ម និងកសិកម្ម។ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)ត្រូវបានរំពឹងថានឹងកើនដល់ ៥១,៣៩ ពាន់លានដុល្លារអាម៉េរិក ជាមួយនឹងប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ចំនួន ២ ៩២៤ដុល្លារអាម៉េរិក ដែលជាការកើនឡើងគួរឱ្យកត់សម្គាល់ពី ២ ៧១៣ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៤។ កំណើន ផ.ស.ស.នេះបង្ហាញពីការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យដឹកជញ្ជូន ក៏ត្រូវបានគេរំពឹងថានឹងរួមចំណែកដល់កំណើនសេដ្ឋកិច្ចផងដែរ។

**រូបភាពទី១៖** ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ឆ្នាំ២០១៧ ដល់ឆ្នាំ២០២៥



ផ្អែកតាមរបាយការណ៍របស់ធនាគារពិភពលោក វិស័យនាំចេញមានការកើនឡើង ១៣,៩% រយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ ២០២៤ ដោយក្នុងនោះមានការរួមចំណែកពីសហរដ្ឋអាមេរិក ៤,១% សហភាពអឺរ៉ុប ២,៧% និង អាស៊ាន ២%[1]។ ភ្ញៀវទេសចរអន្តរជាតិមកប្រទេសកម្ពុជាបានបន្តកើនឡើង ២២,៩% ស្មើនឹង ៦,៧ លាននាក់ ក្នុងឆ្នាំ ២០២៤[2]។ ម្យ៉ាងវិញទៀត យុទ្ធសាស្ត្រក្នុងការទាក់ទាញវិនិយោគិនពីបរទេសរបស់រាជរដ្ឋាភិបាល ក៏ជាផ្នែកមួយដែលជួយជំរុញសេដ្ឋកិច្ចកម្ពុជា។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាពឹងផ្អែកទៅលើវិស័យចម្បងៗចំនួន ៣ ពោលគឺ សេវាកម្ម ឧស្សាហកម្ម និងកសិកម្ម។ ដោយឡែក វិស័យកសិកម្មត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើនប្រមាណ ០,៧% ក្នុងឆ្នាំ២០២៤ និង ១,១% នៅឆ្នាំ២០២៥ នេះ។

**រូបភាពទី២៖** កំណើនផ.ស.ស. និងការងារតាមវិស័យ (ឆ្នាំ២០២៤-២០២៥)




*ប្រភព៖ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

កំណើនការងារក្នុងវិស័យកសិកម្មមានការថយចុះ ៣,៥% ក្នុងឆ្នាំ២០២៤ ហើយត្រូវបានព្យាករថាមានកំណើនអវិជ្ជមានរហូតដល់ឆ្នាំ២០២៥ ខណៈវិស័យឧស្សាហកម្ម មាននិន្នាការវិជ្ជមានដែលផ្តល់ប្រាក់ឈ្នួលខ្ពស់ និងលក្ខខណ្ឌការងារល្អប្រសើរ ហើយបានអូសទាញកម្លាំងពលកម្មចេញពីវិស័យកសិកម្ម។ វិស័យឧស្សាហកម្មត្រូវបានព្យាករថា មានកំណើន ៧,៩% ក្នុងឆ្នាំ ២០២៤ នឹងបន្តកើនឡើងដល់ ៨,៦% នៅឆ្នាំ២០២៥។ ការងើបឡើងវិញនៃ វិស័យនេះ គឺមានការគាំទ្រដោយអនុវិស័យកាត់ដេរ និងអនុវិស័យមិនមែនកាត់ដេរដូចជា ផលិតកម្មចំណីអាហារនិងភេសជ្ជៈ គ្រឿងបង្គុំនិងដំឡើងរថយន្ត និងគ្រឿងបរិក្ខារអេឡិចត្រូនិក។ វិស័យសេវាកម្ម បានបង្ហាញពីសក្តានុពលយ៉ាងខ្លាំង ដោយរំពឹងថានឹងបន្តមានកំណើនវិជ្ជមានរហូតដល់ឆ្នាំ២០២៥ ខណៈអនុវិស័យលក់ដុំ និងលក់រាយ អាចរំពឹងពីកំណើនវិជ្ជមានជាមធ្យមក្នុងរង្វង់ ៥% រវាងឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥។

ជារួម វិស័យចម្បងៗដែលបន្តមានកំណើនវិជ្ជមានក្នុងឆ្នាំបន្ទាប់រួមមាន វិស័យសេវាកម្ម និងវិស័យឧស្សាហកម្ម ដែលនឹងបង្ហាញពីភាពធន់ និងភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងការកើនឡើងនៃចំនួនការងារ និងកម្លាំងពលកម្មក្នុងឆ្នាំបន្តបន្ទាប់ ក្នុងពេលដែលកម្លាំងពលកម្មក្នុងវិស័យកសិកម្មមាននិន្នាការថយចុះ ត្បិតតម្លៃបន្ថែមក្នុងវិស័យនេះបន្តមានកំណើនទាប។

[1] របាយការណ៍ធនាគារពិភពលោក៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែធ្នូ ឆ្នាំ ២០២៤

[2] ក្រសួងទេសចរណ៍៖ ស្ថិតិទេសចរណ៍ ខែធ្នូ ឆ្នាំ២០២៤

## ខ. ស្ថានភាពកម្លាំងពលកម្មកម្ពុជា

នៅក្នុងឆ្នាំ២០២៣ ប្រទេសកម្ពុជាមានប្រជាជនដែលគ្រប់អាយុធ្វើការ (អាយុ ១៥ ទៅ ៦៤ឆ្នាំ) ប្រមាណ ១១,១លាននាក់ ដែលក្នុងនោះស្ត្រីមានចំនួន ៥,៧លាននាក់ និងបុរសមានចំនួន ៥,៤លាននាក់។ ចំនួនអ្នកក្នុងកម្លាំងពលកម្មមានចំនួន ៩,៣លាននាក់ ឬស្មើនឹង ៨៣,៩% នៃប្រជាជនគ្រប់អាយុធ្វើការ និងប្រមាណ ១៦,១% ទៀតជាអ្នកនៅក្រៅកម្លាំងពលកម្ម។ ដូច្នេះ ប្រជាជនកម្ពុជាដែលគ្រប់អាយុធ្វើការបានចូលរួមក្នុងកម្លាំងពលកម្មយ៉ាងច្រើនលើសលប់ ដែលផ្តល់ផលវិជ្ជមានសម្រាប់ការផ្គត់ផ្គង់កម្លាំងពលកម្ម។

**រូបភាពទី៣៖** កម្លាំងពលកម្ម ដែលជាប្រជាជនក្នុងវ័យធ្វើការ (ចាប់ពី១៥ ដល់ ៦៤ឆ្នាំ) ឆ្នាំ២០២៣




*ប្រភព៖ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

| | |
|---|---|
| **ប្រជាជនក្នុងវ័យធ្វើការ** | សំដៅទៅលើមនុស្សទាំងអស់ដែលមានវ័យចន្លោះពី១៥ ដល់ ៦៤ឆ្នាំ។ |
| **អ្នកក្នុងកម្លាំងពលកម្ម** | សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ (ទាំងអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ)។ |
| **អ្នកក្រៅកម្លាំងពលកម្ម** | សំដៅលើ អ្នកក្នុងអាយុធ្វើការទាំងឡាយណា ដែលមិនមានការងារធ្វើ និងមិនស្វែងរកការងារធ្វើក្នុងរយៈពេលជាក់លាក់ណាមួយ ដោយមូលហេតុ ១) ជាប់រៀននៅតាមគ្រឹះស្ថានសិក្សា (សិស្ស/និស្សិត), ២) ជាប់ភារកិច្ចគ្រួសារ ថែទាំសមាជិកគ្រួសារ ឬជាមេផ្ទះ, ចូលនិវត្តន៍ ឬចាស់ជរា, ពិការភាព និងមិនអាចបំពេញការងារបាន និង ៣) ជឿថាគ្មានការងារធ្វើ មិនចង់ធ្វើការ ឬមិនចាប់ផ្តើមការងារក្នុងរយៈពេលខ្លីណាមួយ។ |
| **អ្នកមានការងារធ្វើ** | សំដៅលើ អ្នកមានអាយុ ១៥ឆ្នាំឡើង ដែលក្នុងរយៈពេលមួយអាទិត្យ ឬ៧ថ្ងៃចុងក្រោយ បានចូលរួមក្នុងសកម្មភាពផលិតផលិតផល ឬផ្តល់សេវាកម្ម ដើម្បីទទួលបានប្រាក់ខែ ឬប្រាក់ចំណេញយ៉ាងតិច១ម៉ោង ដោយគិតបញ្ចូលទាំងអ្នកកំពុងធ្វើការក្នុង និងក្រៅប្រទេស និងអ្នកដែលអវត្តមាននៅកន្លែងធ្វើការ ដោយមូលហេតុនៃការឈប់សម្រាកដោយសារមានជំងឺ គ្រោះថ្នាក់ការងារ ការសិក្សាឬការបណ្តុះបណ្តាល និងសម្រាកលំហែរមាតុភាព ឬដោយមូលហេតុផ្សេងៗ។ |

*ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨*

## គ. ការវិនិយោគផ្ទាល់ពីបរទេស(FDI) និងគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIPs)

នៅក្នុងឆ្នាំ២០២៤ លំហូរវិនិយោគសកលបានថយចុះប្រមាណ ២% មកត្រឹម ១,៣ពាន់លានដុល្លារអាម៉េរិកដោយសារការព្រួយបារម្ភរបស់វិនិយោគិនអំពីភាពមិននឹងនរនៃសេដ្ឋកិច្ច និងភាពតានតឹងនៃភូមិសាស្ត្រនយោបាយ។ ការវិនិយោគបរទេសនៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍនៅតំបន់អាស៊ីបានធ្លាក់ចុះប្រមាណ ៨% មកនៅត្រឹម ៦២១ពាន់លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៣។ ដោយឡែក កម្ពុជានៅតែបន្តទទួលបានការវិនិយោគដោយផ្ទាល់ពីបរទេស ដោយបានកើនឡើងពី ៤៤,៥ពាន់លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២២ ដល់ ៥០,៣ពាន់លានដុល្លារអាម៉េរិកនៅពាក់កណ្ដាលឆ្នាំ២០២៤។ កំណើននេះបានបង្ហាញពីទំនុកចិត្តកាន់តែខ្លាំងឡើងពីវិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជា ។ អនុវិស័យហិរញ្ញវត្ថុតែងតែទាក់ទាញការវិនិយោគច្រើនជាងគេ ខណៈពេលដែលអនុវិស័យកម្មន្តសាល ក៏បានបង្ហាញពីកំណើនដ៏រឹងមាំ ស្របតាមយុទ្ធសាស្ត្រតម្រង់ទិសការនាំចេញរបស់កម្ពុជាផងដែរ។

**រូបភាពទី៤៖** ទំហំនៃការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា ២០២២-២០២៤ (គិតជា លានដុល្លារអាម៉េរិក)




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា (២០២៤)*

យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ចំនួនគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIPs) បានងើបឡើងវិញក្នុងសន្ទុះយ៉ាងឆាប់រហ័ស ក្រោយការរាតត្បាតនៃជំងឺកូវីដ-១៩ ដោយកើនពី ១៨៦គម្រោង ក្នុងឆ្នាំ២០២២ ទៅដល់ ៤១៤គម្រោង ឆ្នាំ២០២៤។ គម្រោង QIPs ទាំងនោះ អាចបង្កើតការងារប្រមាណ ៣២៤,៧ពាន់នាក់ ក្នុងឆ្នាំ២០២៤ ដែលក្នុងនោះវិស័យឧស្សាហកម្មមានចំណែកច្រើនជាងវិស័យផ្សេងទៀត (៣០៦,៩ពាន់នាក់)។ កំណើននៃ QIPs និងកម្លាំងពលកម្ម ជាពិសេសក្នុងវិស័យឧស្សាហកម្ម បានបង្ហាញពីតម្រូវការកម្លាំងពលកម្មដែលមានជំនាញកាន់តែខ្ពស់នាពេលអនាគត ដើម្បីគាំទ្រដល់ការវិវត្តដ៏ឆាប់រហ័សនេះ។

**រូបភាពទី៥៖** ចំនួនគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមវិស័យ ២០២២-២០២៤




*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)*

**រូបភាពទី៦៖** ចំនួនការងារដែលបង្កើតដោយគម្រោងQIPs តាមវិស័យ ២០២២-២០២៤ (ពាន់នាក់)




*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)*

## ឃ. មុខរបរមានកំណើនលឿនក្នុងឆមាសទី១ ឆ្នាំ២០២៥

ខណៈដែលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ត្រូវបានព្យាករថានឹងកើនឡើងជាមួយនឹងអត្រា ៦,៣% មុខរបរដែលយើងសង្កេតឃើញថាមានកំណើនតម្រូវការលឿនតាមរយៈការវិភាគ និងស្រាវជ្រាវទាំង២៥ មានដូចខាងក្រោម៖

| ល.រ | | ឈ្មោះមុខរបរ | ពិពណ៌នាអំពីការងារ<br>និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ<br>(ដុល្លារ) |
|---|---|---|---|---|
| ១ |  | អ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ | -គ្រប់គ្រង ត្រួតពិនិត្យរចនាសម្ព័ន្ធ និងសេវាកម្ម ICT<br>-កម្រិតបរិញ្ញាបត្រផ្នែកកុំព្យូទ័រឡើងទៅ | 700 – 1000 |
| ២ |  | នាយកគ្រប់គ្រងការផ្គត់ផ្គង់ការចែកចាយ និងពាក់ព័ន្ធផ្សេងទៀត | -រៀបចំបង្កើតផែនការយុទ្ធសាស្ត្រទីផ្សារ<br>-បរិញ្ញាបត្រផ្នែកគ្រប់គ្រង និងមានបទពិសោធគ្រប់គ្រងផ្នែកលក់ | 500 – 1000 |
| ៣ |  | នាយកគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា | -គ្រប់គ្រងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា<br>-បរិញ្ញាបត្រផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា | 500 – 900 |
| ៤ |  | ភ្នាក់ងារប្រមូលទំនិញចេញ និងដឹកជញ្ជូនចេញ និងបញ្ជូនបន្ត | - រៀបចំការដឹកជញ្ជូន និងឯកសារពន្ធគយ<br>-ថ្នាក់ទី១២ឡើងទៅ និងមានបទពិសោធការងារដឹកជញ្ជូន | 420 – 570 |
| ៥ |  | អ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់ ច្រកដាក់ដប និងដាក់ផ្លាកសញ្ញា | -ប្រតិបត្តិការ និងត្រួតពិនិត្យម៉ាស៊ីន<br>-ថ្នាក់ទី១២ឡើងទៅ និងធ្លាប់ទទួលវគ្គបណ្តុះបណ្តាលការងារ | 208 – 220 |
| ៦ |  | អ្នកបញ្ជាម៉ាស៊ីនដេរ | -ដំណើរការម៉ាស៊ីនដេរ និងប្រមូលផ្តុំសំលៀកបំពាក់<br>-ថ្នាក់ទី១២ឡើងទៅ និងមានបទពិសោធកាត់ដេរ | 208 – 230 |
| ៧ |  | អ្នកបញ្ជាម៉ាស៊ីនធ្វើស្បែកជើង និងម៉ាស៊ីនដែលពាក់ព័ន្ធ | -ដំណើរការម៉ាស៊ីន<br>-ថ្នាក់ទី១២ឡើងទៅ និងធ្លាប់ទទួលវគ្គបណ្តុះបណ្តាលការងារ | 208 – 250 |
| ៨ |  | បុគ្គលិកផ្នែកកត់ត្រាខាងដឹកជញ្ជូន | -រៀបចំឯកសារដឹកជញ្ជូន តាមដាន និងសម្របសម្រួល<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធដឹកជញ្ជូន | 290 – 300 |
| ៩ |  | បុគ្គលិកផ្នែកកត់ត្រាខាងផលិតកម្ម | -តាមដានកាលវិភាគផលិតកម្ម ត្រួតពិនិត្យសារពើភ័ណ្ឌ និងរៀបចំរបាយការណ៍<br>-កម្រិតបរិញ្ញាបត្រឡើងទៅ | 220 – 260 |
| ១០ |  | មន្ត្រីឥណទាន និងប្រាក់កម្ចី | -វាយតម្លៃពាក្យស្នើសុំកម្ចី<br>-កម្រិតបរិញ្ញាបត្ររងឡើងទៅ | 280 – 350 |
| ១១ |  | គ្រូបង្រៀនភាសាផ្សេងទៀត | -រៀបចំមេរៀន និងបង្រៀន<br>-កម្រិតបរិញ្ញាបត្រផ្នែកភាសា | 210 – 400 |

| | | | | |
|---|---|---|---|---|
| ១២ |  | អ្នកបកប្រែអត្ថបទ អ្នកបកប្រែផ្ទាល់មាត់ និងភាសាវិទូដទៃទៀត | -បកប្រែឯកសារផ្សេងៗ<br>-កម្រិតបរិញ្ញាបត្រផ្នែកភាសា និងបទពិសោធបកប្រែ | 420 – 500 |
| ១៣ |  | ជំនួយការគ្រូបង្រៀន | -ជួយគ្រូបង្រៀនក្នុងថ្នាក់និងផ្ដល់ជំនួយដល់សិស្ស<br>-ថ្នាក់ទី១២ឡើងទៅ និងមានបទពិសោធធ្វើការជាមួយកុមារ | 200 – 300 |
| ១៤ |  | យន្តការី និងជាងជួសជុលម៉ាស៊ីនក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម | -ដំឡើង ថែទាំ និងជួសជុលប្រព័ន្ធអគ្គិសនី<br>-វិញ្ញាបនបត្រផ្នែកអគ្គិសនី | 255 – 350 |
| ១៥ |  | ជាងអគ្គិសនីទូទៅ | -ថែទាំ និងជួសជុលប្រព័ន្ធអគ្គិសនី<br>-វិញ្ញាបនបត្រផ្នែកអគ្គិសនី | 225 – 275 |
| ១៦ |  | អ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក | -បង្កើត និងអនុវត្តយុទ្ធសាស្ត្រធនធានមនុស្ស<br>-បរិញ្ញាបត្រផ្នែកធនធានមនុស្ស | 300 – 500 |
| ១៧ |  | អ្នកកាត់សំលៀកបំពាក់ និងតុកាត់ | -បង្កើត គំរូសំលៀកបំពាក់<br>-ថ្នាក់ទី៩ឡើង និងមានបទពិសោធបណ្ដុះបណ្ដាល | 210 – 250 |
| ១៨ |  | អ្នកមើលការខុសត្រូវការផលិតក្នុងរោងចក្រ | -តាមដានកាលវិភាគ និងដំណើរការផលិតកម្ម<br>-ថ្នាក់ទី៩ឡើង និងមានបទពិសោធរៀបចំផែនការផលិតកម្ម | 300 – 500 |
| ១៩ |  | អ្នកបញ្ជាម៉ាស៊ីនផលិតផលិតផលជ័រកៅស៊ូ | -គ្រប់គ្រងដំណើរការ និងត្រួតពិនិត្យម៉ាស៊ីន<br>-ថ្នាក់ទី១២ឡើង និងមានបទពិសោធបណ្ដុះបណ្ដាល | 200 – 250 |
| ២០ |  | អ្នកមើលការខុសត្រូវការិយាល័យ | -គ្រប់គ្រងបុគ្គលិក និងការងាររដ្ឋបាល<br>-ថ្នាក់ទី១២ឡើងទៅ និងមានបទពិសោធការិយាល័យ | 320 – 520 |
| ២១ |  | អ្នករចនាក្រាហ្វិច និងម៉ាលជីមេឌៀ | -បង្កើតការរចនារូបភាព ម៉ាលជីមេឌៀ និងគេហទំព័រ<br>-បរិញ្ញាបត្រផ្នែករចនាក្រាហ្វិច ឬផ្នែកដែលពាក់ព័ន្ធ | 300 – 500 |
| ២២ |  | អ្នកបង្កើតកម្មវិធី និងប្រព័ន្ធកុំព្យូទ័រ | -ដំឡើង ថែទាំ និងដោះស្រាយបញ្ហាប្រព័ន្ធកុំព្យូទ័រ<br>-កម្រិតបរិញ្ញាបត្រផ្នែកកុំព្យូទ័រឡើងទៅ | 375 – 600 |
| ២៣ |  | អ្នកដុតនំ អ្នកធ្វើនំម្សៅ និងដំណាប់ | -មានចំណេះដឹងនៃបច្ចេកទេសរៀបចំអាហារ ភាពច្នៃប្រឌិត<br>-វិញ្ញាបនបត្រធ្វើនំ ឬការបណ្ដុះបណ្ដាលនៅកន្លែងធ្វើការ | 180 – 250 |
| ២៤ |  | គ្រូបង្រៀននៅសាកលវិទ្យាល័យ និងឧត្តមសិក្សា | -រៀបចំចងក្រងឯកសារបង្រៀន និងស្រាវជ្រាវ<br>-បរិញ្ញាបត្រឡើងទៅ និងគរុកោសល្យបង្រៀន | 350 – 500 |
| ២៥ |  | អ្នកបញ្ជាឡានស្ទូច | -បញ្ជាឡានស្ទូច និងឧបករណ៍លើកផ្សេងទៀត<br>-ថ្នាក់ទី៩ឡើងទៅ និងមានបទពិសោធបញ្ជាឡានស្ទូច | 220 – 350 |

## ខ. មុខរបរថយចុះក្នុងឆមាសទី១ ឆ្នាំ២០២៥

ទន្ទឹមគ្នានេះ ការវិភាគ និងស្រាវជ្រាវក៏បានបង្ហាញឱ្យឃើញថាប្រភេទមុខរបរដែលថយចុះគ្រប់វិស័យ ទាំង២៥ ធៀបនឹងឆមាសទី២ ឆ្នាំ២០២៤មានដូចខាងក្រោមៈ

| ល.រ | | ឈ្មោះមុខរបរ | ពិពណ៌នាអំពីការងារ និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ (ដុល្លារ) |
|---|---|---|---|---|
| ១ |  | នាយកគ្រប់គ្រងហិរញ្ញវត្ថុ | -គ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុរបស់ស្ថាប័ន<br>-កម្រិតបរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ | 500 – 1000 |
| ២ |  | នាយកគ្រប់គ្រងសេវាសុខភាព | -គ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរពេទ្យ<br>-សញ្ញាបត្រវេជ្ជបណ្ឌិត និង មានបទពិសោធក្នុងការគ្រប់គ្រង | 500 – 1000 |
| ៣ |  | នាយកគ្រប់គ្រងការលក់ និងទីផ្សារ | -បង្កើត និងអនុវត្តយុទ្ធសាស្ត្រលក់ និងទីផ្សារ<br>-កម្រិតបរិញ្ញាបត្រផ្នែកទីផ្សារ ឬអាជីវកម្ម និងបទពិសោធពាក់ព័ន្ធ | 500 – 800 |
| ៤ |  | នាយកគ្រប់គ្រងការផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ | -បង្កើត និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយ និងទំនាក់ទំនង<br>-សញ្ញាបត្របរិញ្ញាបត្រផ្នែកទីផ្សារ ទំនាក់ទំនងសាធារណៈ ឬវិស័យពាក់ព័ន្ធ និងបទពិសោធពាក់ព័ន្ធ | 500 – 800 |
| ៥ |  | វេជ្ជបណ្ឌិតឯកទេសទូទៅ | -ពិនិត្យ និងព្យាបាលជំងឺទូទៅ<br>-សញ្ញាបត្រវេជ្ជបណ្ឌិត | 370 – 750 |
| ៦ |  | អ្នកវិភាគហិរញ្ញវត្ថុ | -វិភាគទិន្នន័យហិរញ្ញវត្ថុ និងផ្តល់អនុសាសន៍វិនិយោគ<br>-សញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងវិញ្ញាបនបត្រពាក់ព័ន្ធ | 400 – 600 |
| ៧ |  | នាយកគ្រប់គ្រងភោជនីយដ្ឋាន | -គ្រប់គ្រងការងារប្រចាំថ្ងៃក្នុងភោជនីយដ្ឋាន<br>-វគ្គបណ្តុះបណ្តាល ផ្នែកគ្រប់គ្រងភោជនីយដ្ឋាន | 320 – 580 |
| ៨ |  | ឈ្មួញនិងឈ្មួញកណ្តាលខាងមូលប័ត្រ និងហិរញ្ញវត្ថុ | -សម្របសម្រួលការទិញ និងលក់មូលបត្រហិរញ្ញវត្ថុ<br>-បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ ឬអាជ្ញាប័ណ្ណ/វិញ្ញាបនប័ត្រដែលពាក់ព័ន្ធ | 350 – 450 |
| ៩ |  | ជំនួយការគណនេយ្យករ | -ជួយគណនេយ្យករក្នុងការកត់ត្រា និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ<br>-សញ្ញាបត្រមធ្យមសិក្សា និងការបណ្តុះបណ្តាលផ្នែកគណនេយ្យ | 220 – 350 |
| ១០ |  | បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី | -រក្សាកំណត់ត្រាហិរញ្ញវត្ថុ និងរៀបចំរបាយការណ៍<br>-ថ្នាក់ទី១២ឡើងទៅ ធ្លាប់ទទួលវគ្គបណ្តុះបណ្តាលផ្នែកគណនេយ្យ | 270 – 350 |
| ១១ |  | វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ | -បង្កើត និងអនុវត្តយុទ្ធនាការទីផ្សារឌីជីថល<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធផ្នែកលក់ | 270 – 350 |

| | | | | |
|---|---|---|---|---|
| ១២ |  | អ្នកបើកបររថយន្តធុនតូច និងធុនធំ | -ដឹកជញ្ជូនទំនិញ និងសម្ភារៈ<br>-ប័ណ្ណបើកបរដែលមានសុពលភាព | 180 – 240 |
| ១៣ |  | បុគ្គលិក ឬជំនួយការផ្នែកធនធានមនុស្ស | -ជួយការជ្រើសរើសបុគ្គលិក ការរៀបចំឯកសារពាក់ព័ន្ធ<br>-ថ្នាក់ទី១២ឡើងទៅ និងការបណ្តុះបណ្តាលផ្នែកធនធានមនុស្ស | 220 – 350 |
| ១៤ |  | បុគ្គលិកការិយាល័យទូទៅ | - បំពេញការងាររដ្ឋបាលទូទៅ ដូចជាការដាក់ឯកសារ ការបញ្ចូលទិន្នន័យ និងការឆ្លើយទូរស័ព្ទ<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធការងាររដ្ឋបាល | 220 – 350 |
| ១៥ |  | គ្រូបង្រៀនតន្ត្រីផ្សេងទៀត | - បង្រៀនទ្រឹស្តីតន្ត្រី ឧបករណ៍ភ្លេង ឬបច្ចេកទេសសម្លេង<br>-បរិញ្ញាបត្រផ្នែកអប់រំតន្ត្រី ឬវិញ្ញាបនបត្របង្រៀនតន្ត្រី | 200 – 300 |
| ១៦ |  | អ្នកទទួលភ្ញៀវក្នុងសណ្ឋាគារ | -ទទួលភ្ញៀវ និងផ្តល់សេវាកម្មអតិថិជន<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធក្នុងការផ្តល់សេវាកម្មអតិថិជន | 150 – 250 |
| ១៧ |  | វិជ្ជាជីវៈខាងឆ្មប | -ផ្តល់ការថែទាំដល់ស្ត្រីមានផ្ទៃពោះ ការសម្រាលកូន<br>-បរិញ្ញាបត្រ ឬអនុបណ្ឌិតផ្នែកឆ្មប និងវិញ្ញាបនបត្រឆ្មបដែលបានចុះបញ្ជី | 300 – 470 |
| ១៨ |  | បុគ្គលិកផ្នែកកត់ត្រាខាងស្តុកទំនិញ | -គ្រប់គ្រងស្តុកទំនិញ ទទួល និងចែកចាយសម្ភារៈ<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធក្នុងការគ្រប់គ្រងស្តុកទំនិញ | 220 – 400 |
| ១៩ |  | អ្នកបញ្ជាម៉ាស៊ីនផលិតផលិតផលប្លាស្ទិក | -បញ្ជា និងត្រួតពិនិត្យម៉ាស៊ីនផលិតផលិតផលប្លាស្ទិក<br>-វគ្គបណ្តុះបណ្តាល និងបទពិសោធក្នុងការប្រើប្រាស់ម៉ាស៊ីនផលិតផលិតផលប្លាស្ទិក | 220 – 250 |
| ២០ |  | គ្រូបង្រៀននៅថ្នាក់មធ្យមសិក្សា | -បង្រៀនមុខវិជ្ជានៅថ្នាក់មធ្យមសិក្សា<br>-បរិញ្ញាបត្រផ្នែកអប់រំ និងវិញ្ញាបនបត្របង្រៀន | 250 – 400 |
| ២១ |  | អ្នកអប់រំកុមារតូចៗ | -បង្រៀន និងថែទាំកុមារតូចៗ នៅក្នុងសាលាមត្តេយ្យ<br>-បរិញ្ញាបត្រផ្នែកអប់រំកុមារ ឬវិញ្ញាបនបត្រពាក់ព័ន្ធ | 200 – 400 |
| ២២ |  | អ្នកក្រឡុកស្រា | -ផ្តល់សេវាកម្មរៀបចំ និងបម្រើភេសជ្ជៈ<br>-វគ្គបណ្តុះបណ្តាល | 125 – 200 |
| ២៣ |  | ជំនួយការមេចុងភៅ | -ជួយមេចុងភៅក្នុងធ្វើម្ហូបអាហារ និងថែរក្សាអនាម័យ<br>-បទពិសោធក្នុងការចម្អិនអាហារ ចំណេះដឹងអំពីបច្ចេកទេសចម្អិនអាហារ | 150 – 300 |
| ២៤ |  | ជាងដំឡើងបំពង់ទុយោទឹក បំពង់ទុយោឧស្ម័ន និងបំពង់ទុយោខ្យល់ | -ដំឡើង ថែទាំ និងជួសជុលប្រព័ន្ធទឹក និងលូ<br>-ថ្នាក់ទី១២ឡើង និង បណ្តុះបណ្តាលវិជ្ជាជីវៈ ឬកម្មសិក្សាផ្នែកបំពង់ទុយោ | 210 – 300 |
| ២៥ |  | បេឡាធិការនៅធនាគារ | -ទទួលប្រាក់បញ្ញើ ដកប្រាក់ ផ្ទេរប្រាក់ និងផ្តល់សេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀតដល់អតិថិជន<br>-ថ្នាក់ទី១២ឡើងទៅ និងជំនាញទំនាក់ទំនងល្អ | 250 – 350 |

## ផ្នែកទី២៖ ការព្យាករនៃតម្រូវការការងារនៅកម្ពុជាក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម

ការព្យាករនៃអត្រាកំណើនផ.ស.ស.ជាមធ្យមរង្វង់ ៦,៣% ចន្លោះឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥ បានបង្ហាញពីការបង្កើតឱកាសការងារជាច្រើននៅក្នុងវិស័យចម្បងរបស់កម្ពុជា ជាពិសេសវិស័យសេវាកម្ម និងឧស្សាហកម្ម ខណៈចំនួនការងារក្នុងវិស័យកសិកម្មនៅតែរក្សានិន្នាការថយចុះ។ ចំនួនការងារសរុប ត្រូវបានព្យាករថានឹងកើនពី ៩,៨លាននាក់ ក្នុងឆ្នាំ២០២៣ ដល់ ១០,១លាននាក់ ក្នុងឆ្នាំ២០២៥ ជាពិសេសក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម។

**រូបភាពទី៧៖** អនុវិស័យសំខាន់ៗក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម




*កំណត់ចំណាំ៖*

- *ព័ត៌មានក្រុមហ៊ុនចុះបញ្ជី, ម្ចាស់ក្រុមហ៊ុន និងទំហំក្រុមហ៊ុនមានប្រភពមកពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័ការងារ (LACMS) របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។*
- *ព័ត៌មានក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស, ចំនួនជ្រើសរើស, ការផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធ, ឱកាសការងារ, ការលំបាកក្នុងការជ្រើសរើស, កង្វះខាតជំនាញ, បញ្ហាគម្លាតជំនាញ, មុខតំណែងឱកាសល្អ, ជំនាញរឹង និងជំនាញទន់ មានប្រភពមកពីការអង្កេត «**ទស្សនវិស័យការងារកម្ពុជា**» **ឆមាសទី១ ឆ្នាំ២០២៥** របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។*

**អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន៖** ក្នុងឆមាសទី១ ឆ្នាំ២០២៥ ៦១,១% នៃក្រុមហ៊ុនសរុបក្នុងអនុវិស័យស្នាក់នៅ និងភោជនីយដ្ឋានកំពុងប្រកាសជ្រើសរើសបុគ្គលិក និងត្រូវបានរំពឹងទុកថាចំនួនបុគ្គលិកដែលនឹងត្រូវជ្រើសរើសមាន ២ ២៦៨ មុខតំណែង។ អាជីវកម្មភាគច្រើននៅក្នុងអនុវិស័យនេះមានទំហំតូចដល់មធ្យម ដែលផ្តល់ឱកាសដល់អ្នកកំពុងស្វែងរកការងារដំបូង។ បន្ថែមពីនេះ អ្នកដែលចង់ស្វែងរកការងារក្នុងអនុវិស័យនេះ គួរតែផ្តោតលើការអភិវឌ្ឍទាំងជំនាញទន់ និងជំនាញបច្ចេកទេស ដែលមានតម្រូវការខ្ពស់។ ជំនាញទន់សំខាន់ៗ រួមមានជំនាញដោះស្រាយបញ្ហា ការគ្រប់គ្រងអតិថិជន និងជំនាញទំនាក់ទំនង ខណៈជំនាញបច្ចេកទេសសំខាន់ៗ រួមមានជំនាញភាសាអង់គ្លេស ការត្រួតពិនិត្យប្រតិបត្តិការ និងជំនាញគណនេយ្យ និងហិរញ្ញវត្ថុ។ គួរឱ្យកត់សម្គាល់ផងដែរថា ៤៥,២% នៃក្រុមហ៊ុនសរុបបានរាយការណ៍ថាមានមុខតំណែងទំនេរដែលពិបាកក្នុងការបំពេញ ដោយសារតែការប្រកួតប្រជែងខ្ពស់ពីនិយោជកផ្សេងទៀត និងចំនួនបេក្ខជនដាក់ពាក្យតិច។

**រូបភាពទី៨៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យអប់រំ៖** អនុវិស័យនេះបង្ហាញពីកំណើនគួរឱ្យកត់សម្គាល់ជាមួយនឹងក្រុមហ៊ុនដែលបានចុះបញ្ជីចំនួន ៨៦៦ ក្នុងឆមាសទី១ ឆ្នាំ២០២៥ កើនឡើងពីចំនួន ៨០៤ នៅឆមាសទី២ ឆ្នាំ២០២៤។ ក្រុមហ៊ុនប្រមាណ ៧៧,៥% កំពុងប្រកាសជ្រើសរើសបុគ្គលិក ហើយចំនួនឱកាសការងារសរុបក្នុងអនុវិស័យនេះមាន ១ ៦៩០កន្លែង។ ក្រុមហ៊ុនប្រមាណ ៤៣% បានផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធចូលបម្រើការងារ។ ជំនាញទន់ដែលមានតម្រូវការច្រើនជាងគេគឺ ជំនាញដោះស្រាយបញ្ហា ការទំនាក់ទំនងផ្ទាល់មាត់ ការគ្រប់គ្រងអតិថិជន ការសម្របសម្រួល និងការគ្រប់គ្រងពេលវេលា ខណៈដែលជំនាញបច្ចេកទេសសំខាន់ៗ រួមមានជំនាញភាសាអង់គ្លេស ការគ្រប់គ្រងធនធានមនុស្ស ទីផ្សារឌីជីថល រដ្ឋបាលការិយាល័យ និងការគ្រប់គ្រងគុណភាព។ ទោះជាយ៉ាងនេះក្តី អ្នកស្វែងរកការងារគួរតែដឹងពីបញ្ហាប្រឈមមួយចំនួននៅក្នុងអនុវិស័យនេះ ដោយ ៣៣,២% នៃក្រុមហ៊ុនបានរាយការណ៍ថាមានគម្លាតជំនាញ ហើយ ២៤,៣% បានរាយការណ៍ពីការលំបាកក្នុងការជ្រើសរើសបុគ្គលិកមកធ្វើការក្នុងក្រុមហ៊ុនរបស់ពួកគេ។

**រូបភាពទី៩៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យអប់រំ ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង៖** អនុវិស័យនេះមានក្រុមហ៊ុនចុះបញ្ជីចំនួន ៤ ១៤៥ ក្នុងឆមាសទី១ ឆ្នាំ២០២៥ ដោយមានក្រុមហ៊ុនប្រមាណ ៧៨% កំពុងប្រកាសជ្រើសរើសបុគ្គលិក។ តម្រូវការកម្លាំងពលកម្មមានការកើនឡើងយ៉ាងច្រើន ពី ១ ៦២៦ ដល់ ៥ ៨៣៦នាក់ ដែលបង្ហាញពីសក្តានុពល និងការពង្រីកឱកាសការងារនៃអនុវិស័យនេះ។ ជំនាញទន់សំខាន់ៗ រួមមានជំនាញដោះស្រាយបញ្ហា ការគ្រប់គ្រងអតិថិជន និងជំនាញទំនាក់ទំនងផ្ទាល់មាត់។ សម្រាប់សមត្ថភាពបច្ចេកទេស អ្នកស្វែងរកការងារគួរតែផ្តោតលើការអភិវឌ្ឍជំនាញគណនេយ្យ និងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស ការត្រួតពិនិត្យប្រតិបត្តិការ និងជំនាញភាសាអង់គ្លេស។ ការលំបាកក្នុងការជ្រើសរើសបុគ្គលិក បានថយចុះប្រមាណ ៤,៦ ពិន្ទុភាគរយ មកត្រឹម ១៧,៣% នៅឆមាសទី១ ឆ្នាំ២០២៥នេះ។ យ៉ាងណាមិញ ២៥,៨% នៃក្រុមហ៊ុនសរុបបានរាយការណ៍ថាមានគម្លាតជំនាញ ខណៈពេលដែលមានតែ ១២,៩% ប៉ុណ្ណោះ ដែលផ្តល់ឱកាសការងារឱ្យអ្នកគ្មានបទពិសោធ។

**រូបភាពទី១០៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យសុខាភិបាល៖** អនុវិស័យនេះមានក្រុមហ៊ុនចុះបញ្ជីចំនួន ៦៨២នៅក្នុងប្រព័ន្ធ LACMS ក្នុងឆមាសទី១ ឆ្នាំ ២០២៥ ដែលភាគច្រើននៃម្ចាស់ក្រុមហ៊ុនមានសញ្ជាតិខ្មែរ (៨២,៧%)។ អនុវិស័យនេះបង្ហាញពីសកម្មភាពជ្រើសរើសបុគ្គលិកខ្ពស់ ដោយមាន ៤១,២% នៃក្រុមហ៊ុនសរុបបានប្រកាសជ្រើសរើសបុគ្គលិក។ បើទោះបីជាភាគរយនៃក្រុមហ៊ុនដែលកំពុងជ្រើសរើសបុគ្គលិកមានការថយចុះ(-២,៧%)ក៏ពិតមែន ប៉ុន្តែយើងនៅតែសង្កេតឃើញថាឱកាសការងារនៅក្នុងអនុវិស័យនេះមានតម្រូវការខ្ពស់ (ស្ទើរតែពាក់កណ្តាលនៃក្រុមហ៊ុនទាំងអស់នៅក្នុងអនុវិស័យនេះ កំពុងប្រកាសជ្រើសរើសបុគ្គលិក) ដូចនេះយុវជន គួរពិចារណាសិក្សាទាំងជំនាញទន់ និងជំនាញបច្ចេកទេសដែលចាំបាច់ សម្រាប់អនុវិស័យនេះដើម្បីទទួលបានឱកាសបម្រើការងារនៅក្នុងមុខតំណែងល្អៗ ដែលមានតម្រូវការខ្ពស់នៅក្នុងទីផ្សារការងារ ទោះជាយ៉ាងណាក៏ដោយ ២៤,៤% នៃក្រុមហ៊ុនសរុបបានរាយការណ៍ថាមានការលំបាកក្នុងការជ្រើសរើសបុគ្គលិក។

**រូបភាពទី១១៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យសុខាភិបាល ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT)៖** ក្នុងឆមាសទី១ ឆ្នាំ២០២៥ អនុវិស័យ ICT នៅកម្ពុជា បង្ហាញពីឱកាសការងារដែលមាននិន្នាការវិជ្ជមាន កើនឡើងប្រមាណ ៣៧,៦ ពិន្ទុភាគរយ បើប្រៀបធៀបនឹងឆមាសទី២ ឆ្នាំ២០២៤។ ប៉ុន្តែ កត្តាគម្លាតជំនាញនៅតែជាបញ្ហាប្រឈម។ គិតត្រឹមដើមឆ្នាំ២០២៥ មានក្រុមហ៊ុនចុះបញ្ជីចំនួន ១ ៦៣០ ក្រុមហ៊ុន ដែលក្នុងនោះភាគច្រើនជាសហគ្រាសធុនតូច និងមធ្យម។ បច្ចុប្បន្ននេះ ៧០,៦% នៃក្រុមហ៊ុនសរុប កំពុងប្រកាសជ្រើសរើសបុគ្គលិក ដែលបង្ហាញពីសក្តានុពលទីផ្សារការងារខ្លាំង។ ដោយឡែក ជំនាញទន់សំខាន់ៗរួមមាន ការទំនាក់ទំនងផ្ទាល់មាត់ ការដោះស្រាយបញ្ហា ការសម្របសម្រួល និងការគ្រប់គ្រងពេលវេលា ខណៈជំនាញបច្ចេកទេសផ្តោតលើជំនាញកុំព្យូទ័រជាមូលដ្ឋាន ការដោះស្រាយបញ្ហាប្រព័ន្ធ និងសុវត្ថិភាពតាមអ៊ីនធឺណិត ជំនាញទីផ្សារឌីជីថល ចំណេះដឹងផ្នែកច្បាប់ និងការវិភាគប្រព័ន្ធ។ ជាមួយនឹងចំនួនការជ្រើសរើសបុគ្គលិកដែលរំពឹងទុកចំនួន ២០៥កន្លែង និងសន្ទស្សន៍ស្ថានភាពជ្រើសរើសកម្លាំងពលកម្មបង្ហាញពីឱកាសច្រើនសម្រាប់អ្នកដែលមានជំនាញទន់ និងជំនាញបច្ចេកទេសខាងលើ។

**រូបភាពទី ១២៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី៖** អនុវិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដោយក្រុមហ៊ុនដែលបានចុះបញ្ជីបានកើនឡើងពី ១៤៦ ដល់ ២៣៣ សម្រាប់ឆមាសទី១ ឆ្នាំ២០២៥។ ជាង ៦០% នៃក្រុមហ៊ុនសរុបកំពុងជ្រើសរើសបុគ្គលិកបន្ថែម ហើយចំនួនឱកាសការងារក៏ត្រូវបានរំពឹងថាមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាមួយកំណើនដល់ ៦ ១២៨កន្លែងក្នុងឆមាសថ្មីនេះ។ បញ្ហាទាក់ទងកង្វះខាតជំនាញ និងបញ្ហាលំបាកក្នុងការជ្រើសរើសបុគ្គលិកមានការថយចុះ ក៏ប៉ុន្តែបញ្ហាគម្លាតជំនាញមានការកើនឡើង បើធៀបនឹងឆមាសមុន។ ដើម្បីឱ្យស្របតាមតម្រូវការជំនាញក្នុងអនុវិស័យនេះ អ្នកស្វែងរកការងារធ្វើ និងនិស្សិតដែលទើបបញ្ចប់ការសិក្សាថ្មីៗ គួរអភិវឌ្ឍជំនាញទន់ដូចជាជំនាញដោះស្រាយបញ្ហា សម្របសម្រួល ការគ្រប់គ្រងពេលវេលា ការត្រួតពិនិត្យ និងជំនាញទំនាក់ទំនងផ្ទាល់មាត់ ព្រមទាំងជំនាញបច្ចេកទេសដូចជា ការត្រួតពិនិត្យគុណភាព ការគ្រប់គ្រងធនធានមនុស្ស ជំនាញកុំព្យូទ័រជាមូលដ្ឋាន សមត្ថភាពភាសាចិន និងភាសាអង់គ្លេស។

**រូបភាពទី១៣៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យដឹកជញ្ជូន ឃ្លាំង និងភស្តុភារ៖** អនុវិស័យនេះមានក្រុមហ៊ុនចុះបញ្ជីចំនួន ១ ៣៦១ សម្រាប់ឆមាសទី១ ឆ្នាំ២០២៥ ដែលក្នុងនោះ ៧១,២% គ្រប់គ្រងដោយម្ចាស់ក្រុមហ៊ុនសញ្ជាតិខ្មែរ។ ខណៈដែលចំនួនក្រុមហ៊ុនដែលកំពុងជ្រើសរើសបុគ្គលិកមាន ៥៨,២% សម្រាប់ឆមាសទី១ ឆ្នាំ២០២៥នេះ ប៉ុន្តែចំនួននៃការជ្រើសរើសបុគ្គលិកថយចុះរហូតដល់ ៦ ៦៣៥ កន្លែង (ពី ៧ ៦២០ មកត្រឹម ៩៨៥ កន្លែង) ដោយសារការលំបាកក្នុងការជ្រើសរើសបុគ្គលិកមានការកើនឡើងប្រមាណជា ១០,១ ពិន្ទុភាគរយ ធៀបនឹងឆមាសមុន។ ដូច្នេះអ្នកស្វែងរកការងារគួរចាប់យកជំនាញបច្ចេកទេស ដែលឆ្លើយតបនឹងតម្រូវការរបស់និយោជកដើម្បីទទួលបានឱកាសការងារល្អ។

**រូបភាពទី១៤៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យដឹកជញ្ជូន ឃ្លាំង និងភស្តុភារ ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យសំណង់៖** អនុវិស័យសំណង់បង្ហាញពីឱកាសសម្រាប់និស្សិតដែលទើបបញ្ចប់ការសិក្សា និងអ្នកស្វែងរកការងារធ្វើ ដោយ ៤១,៧% នៃក្រុមហ៊ុនសរុបកំពុងប្រកាសជ្រើសរើសបុគ្គលិក នៅឆមាសទី១ ឆ្នាំ២០២៥ ហើយអនុវិស័យនេះអាចនឹងជ្រើសរើសបុគ្គលិកសរុបប្រមាណ ១ ០៤០កន្លែង។ ក្រុមហ៊ុនប្រមាណ ៥,៨% រាយការណ៍ថាជួបប្រទះបញ្ហាគម្លាតជំនាញ ហើយ ៥,៣% ប្រឈមមុខនឹងបញ្ហាកង្វះជំនាញ។ ជំនាញទន់សំខាន់ៗ រួមមាន ការដោះស្រាយបញ្ហា ការត្រួតពិនិត្យ ការសម្របសម្រួល ការគ្រប់គ្រងអតិថិជន និងជំនាញទំនាក់ទំនងផ្ទាល់មាត់ ខណៈដែលជំនាញបច្ចេកទេសដែលមានតម្រូវការបំផុតគឺ ទីផ្សារឌីជីថល ការត្រួតពិនិត្យប្រតិបត្តិការ គណនេយ្យ និងហិរញ្ញវត្ថុ ការគ្រប់គ្រងគុណភាព និងជំនាញភាសាអង់គ្លេស។ អ្នកស្វែងរកការងារដែលមានជំនាញជាក់លាក់ទាំងនេះ អាចមានលក្ខណសម្បត្តិប្រកួតប្រជែង ដើម្បីទទួលបានឱកាសការងារល្អក្នុងអនុវិស័យសំណង់នេះ។

**រូបភាពទី១៥៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យសំណង់ ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប៖** បច្ចុប្បន្ន អនុវិស័យនេះមានក្រុមហ៊ុនចុះបញ្ជីចំនួន ១ ៥៦៦ ដែល ១៥,៨% នៃម្ចាស់ក្រុមហ៊ុនជាសញ្ជាតិខ្មែរ។ ក្រុមហ៊ុនប្រមាណ ៦៧,២% កំពុងប្រកាសជ្រើសរើសបុគ្គលិក ជាមួយនឹងការរំពឹងទុកនៃឱកាសការងារចំនួនជាង ៥៣ពាន់កន្លែង ដែលកើនឡើងជិត ២០ពាន់កន្លែង ធៀបនឹងឆមាសទី២ ឆ្នាំ២០២៤។ ជំនាញទន់សំខាន់ៗ រួមមាន ការដោះស្រាយបញ្ហា ការត្រួតពិនិត្យ ការសម្របសម្រួល ការគ្រប់គ្រងពេលវេលា និងការដោះស្រាយបញ្ហាអតិថិជន។ សម្រាប់សមត្ថភាពបច្ចេកទេស និយោជកឱ្យតម្លៃលើការគ្រប់គ្រងធនធានមនុស្ស ជំនាញភាសាចិន ការវិភាគការគ្រប់គ្រងគុណភាព ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ និងការត្រួតពិនិត្យប្រតិបត្តិការ។ ដោយមើលឃើញថា ៤២,២% នៃក្រុមហ៊ុនបានរាយការណ៍ពីការលំបាកក្នុងការជ្រើសរើសបុគ្គលិក ហើយ ១៣,៣% កំពុងប្រឈមនឹងការខ្វះខាតជំនាញ អ្នកស្វែងរកការងារដែលអភិវឌ្ឍជំនាញជាក់លាក់ខាងលើនឹងមានគុណសម្បត្តិប្រកួតប្រជែងក្នុងការទទួលការងារក្នុងវិស័យនេះ។

**រូបភាពទី១៦៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យផលិតអាហារ និងភេសជ្ជៈ៖** អនុវិស័យនេះបានបង្ហាញពីកំណើនគួរឱ្យកត់សម្គាល់ ដោយក្រុមហ៊ុនដែលបានចុះបញ្ជីបានកើនឡើងដល់ ៦៦៤ ក្នុងឆមាសទី១ ឆ្នាំ២០២៥។ ម្ចាស់ក្រុមហ៊ុនភាគច្រើនជាជនជាតិខ្មែរ (៧៥,៨%)។ សម្រាប់អ្នកស្វែងរកការងារធ្វើ ជាពិសេសនិស្សិតទើបបញ្ចប់ការសិក្សា មានទាំងឱកាស និងបញ្ហាប្រឈមដែលត្រូវពិចារណា។ ជំនាញទន់ដែលចាំបាច់ រួមមានការគ្រប់គ្រងអតិថិជន ការដោះស្រាយបញ្ហា ការត្រួតពិនិត្យ ជំនាញទំនាក់ទំនងផ្ទាល់មាត់ និងការគ្រប់គ្រងពេលវេលា។ ជំនាញបច្ចេកទេសរួមមានការវិភាគការត្រួតពិនិត្យគុណភាព ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ ការត្រួតពិនិត្យប្រតិបត្តិការ ការគ្រប់គ្រងធនធានមនុស្ស និងជំនាញភាសាអង់គ្លេស។ ខណៈពេលដែលចំណែកនៃក្រុមហ៊ុនកំពុងជ្រើសរើសបុគ្គលិកមាន ៤៥,៧% និងការលំបាកក្នុងការជ្រើសរើសបុគ្គលិកមានការកើនឡើងគួរឱ្យកត់សម្គាល់ (៣៧,៤%) និងក្រុមហ៊ុនប្រមាណ ១៦,០% ជួបប្រទះបញ្ហាកង្វះជំនាញ។ ដូច្នេះអ្នកស្វែងរកការងារគួរផ្តោតលើជំនាញជាក់លាក់ ដើម្បីបង្កើនលទ្ធភាពទទួលបានការងារល្អរបស់ពួកគេ។

**រូបភាពទី១៧៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យផលិតអាហារ និងភេសជ្ជៈ ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យផលិតកៅស៊ូ និងប្លាស្ទិក៖** ចំនួនក្រុមហ៊ុនដែលបានចុះបញ្ជីសរុបក្នុងអនុវិស័យនេះបានកើនដល់ ២០៨ សម្រាប់ឆមាសទី១ ឆ្នាំ២០២៥។ ឱកាសការងារក្នុងអនុវិស័យនេះមានចំនួន ៥២៩កន្លែង ដែលតិចជាងឆមាសទី២ ឆ្នាំ២០២៤ ប៉ុន្តែ ២២,៤% នៃក្រុមហ៊ុនផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធចូលធ្វើការ ដែលបង្ហាញពីការបើកចំហរចំពោះសិស្ស និស្សិតទើបបញ្ចប់ការសិក្សា។ ជំនាញទន់សំខាន់ៗ រួមមាន ការគ្រប់គ្រងពេលវេលា ការត្រួតពិនិត្យ ការដោះស្រាយបញ្ហា ការសម្របសម្រួល និងជំនាញទំនាក់ទំនងផ្ទាល់មាត់ ខណៈ ជំនាញបច្ចេកទេស រួមមានការគ្រប់គ្រងគុណភាព ការត្រួតពិនិត្យប្រតិបត្តិការ ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ ភាសាចិន និងជំនាញភាសាអង់គ្លេស។ យ៉ាងណាមិញ ក្រុមហ៊ុនដែលមានការលំបាកក្នុងការជ្រើសរើសបុគ្គលិកបានកើនដល់ ២៥,៩% ហើយក្រុមហ៊ុនដែលជួបបញ្ហាកង្វះខាតជំនាញកើនឡើងដល់១៧,៧%។

**រូបភាពទី១៨៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យផលិតកៅស៊ូ និងប្លាស្ទិក ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យផលិតឈើ ក្រដាស និងបោះពុម្ព៖** ចំនួនក្រុមហ៊ុនដែលបានចុះបញ្ជីសរុបក្នុងអនុវិស័យនេះបានកើនឡើងដល់ ២២៥ ក្នុងឆមាសទី១ ឆ្នាំ២០២៥ នេះ។ ក្រុមហ៊ុនប្រមាណ ៥៩,៧% កំពុងជ្រើសរើសបុគ្គលិក ដែលក្នុងនោះ ២០,១% មានការលំបាកក្នុងការជ្រើសរើសបុគ្គលិក ដែលការណ៍នេះបង្ហាញពីភាពមិនស៊ីគ្នារវាងនៃជំនាញ និងតម្រូវការការងារ។ ជំនាញទន់ដែលមានតម្រូវការរួមមាន ការត្រួតពិនិត្យ ការដោះស្រាយបញ្ហា ការគ្រប់គ្រងពេលវេលា ការគ្រប់គ្រងអតិថិជន និងជំនាញទំនាក់ទំនងផ្ទាល់មាត់។ សម្រាប់ជំនាញបច្ចេកទេសសំខាន់ៗមាន ភាសាចិន ការវិភាគការគ្រប់គ្រងគុណភាព ការត្រួតពិនិត្យប្រតិបត្តិការ ការគ្រប់គ្រងធនធានមនុស្ស និងជំនាញគណនេយ្យ និងហិរញ្ញវត្ថុ។ សន្ទស្សន៍ឱកាសការងារនៅតែស្ថិតក្នុងកម្រិតមធ្យម ហើយមិនមានការប្រែប្រួលច្រើនទេ បើប្រៀបធៀបនឹងឆមាសមុន។

**រូបភាពទី១៩៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យផលិតឈើ ក្រដាស និងបោះពុម្ព ក្នុងឆមាសទី១ ឆ្នាំ២០២៥



**អនុវិស័យកម្មន្តសាលផ្សេងៗ៖** ផ្អែកលើទិន្នន័យពីប្រព័ន្ធ LACMS និងការអង្កេតនិយោជក អនុវិស័យកម្មន្តសាលផ្សេងៗ មានក្រុមហ៊ុនចុះបញ្ជីចំនួន ១ ៤០១។ ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើសបុគ្គលិកមានការកើនឡើងគួរឱ្យកត់សម្គាល់ដល់ ៧៣,៨% ហើយ ៣១,១% នៃក្រុមហ៊ុនសរុបផ្តល់ឱកាសការងារដល់អ្នកដែលមិនមានបទពិសោធ។ ២០,៨% នៃក្រុមហ៊ុនសរុបបានរាយការណ៍ថាជួបបញ្ហាគម្លាតជំនាញ ហើយ ៣២,៦% ទៀតបានរាយការណ៍ពីការលំបាកក្នុងការជ្រើសរើសបុគ្គលិក។ ជំនាញទន់ដែលនិយោជកស្វែងរកគឺ ជំនាញដោះស្រាយបញ្ហា ជំនាញទំនាក់ទំនងផ្ទាល់មាត់ ការគ្រប់គ្រងអតិថិជន ជំនាញទំនាក់ទំនង និងការត្រួតពិនិត្យ។ ជំនាញរឹងដែលសំខាន់ៗរួមមាន ការត្រួតពិនិត្យប្រតិបត្តិការ ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ ជំនាញមូលដ្ឋានគ្រឹះកុំព្យូទ័រ ការគ្រប់គ្រងធនធានមនុស្ស និងជំនាញភាសាអង់គ្លេស។

**រូបភាពទី២០៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យកម្មន្តសាលផ្សេងៗ ក្នុងឆមាសទី១ ឆ្នាំ២០២៥



## ផ្នែកទី៣៖ តម្រូវការមុខរបរក្នុងទីផ្សារការងារតាមកម្រិតនៃជំនាញ និងមុខតំណែង

មុខរបរដែលមានតម្រូវការទីផ្សារការងារខ្ពស់ ត្រូវបានដកស្រង់ចេញពីមុខរបរសរុបចំនួន ២៥៦ ដែលមាននៅក្នុងអនុវិស័យទាំង១៣ ខាងលើ។ ការបែងចែកមុខរបរទៅតាមកម្រិតជំនាញ និងមុខតំណែងនេះ អាចជួយឱ្យការជ្រើសរើសមុខរបរដែលមានសក្តានុពល និងឱកាសការងារល្អ អាចកំណត់ទិសដៅ និងផែនការអាជីពរបស់ខ្លួនបានកាន់តែច្បាស់លាស់ ដោយផ្តោតលើការអភិវឌ្ឍជំនាញ និងបទពិសោធដែលសមស្របទៅតាមសក្តានុពល និងចំណាប់អារម្មណ៍របស់ខ្លួន។ ការស្វែងយល់ពីឱកាសការងារ និងមុខរបរដែលមានតម្រូវការខ្ពស់ត្រូវបានបែងចែកជាកម្រិតជំនាញ មុខតំណែង កម្រិតនៃការសិក្សា និងបទពិសោធការងារ ដូចក្នុងតារាងខាងក្រោម។

**តារាងទី១៖** មុខរបរដែលមានតម្រូវការខ្ពស់ តាមកម្រិតជំនាញ

| | | | | | |
|---|---|---|---|---|---|
| **អ្នកគ្រប់គ្រង៖** ជាកម្រិតអ្នកដឹកនាំស្ថាប័ន ដែលទាមទារកម្រិតអប់រំចាប់ពី បរិញ្ញាបត្រឡើងទៅ និងមានបទពិសោធយ៉ាងតិច ១០ឆ្នាំ | នាយកគ្រប់គ្រងធនធានមនុស្ស  | នាយកគ្រប់គ្រងសេវាពាណិជ្ជកម្ម  | នាយកគ្រប់គ្រងការផ្គត់ផ្គង់ការចែកចាយ  | នាយកគ្រប់គ្រងការរៀបចំផែនការ និងគោលនយោបាយ  | នាយកគ្រប់គ្រងបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា  |
| **អ្នកជំនាញជាន់ខ្ពស់ និងអ្នកឯកទេស៖** ជាកម្រិតអ្នកជំនាញជាន់ខ្ពស់ និងអ្នកឯកទេស ដែលទាមទារកម្រិតអប់រំចាប់ពីបរិញ្ញាបត្រឡើងទៅ និងមានបទពិសោធយ៉ាងតិច ៥ឆ្នាំ | អ្នកជំនាញខាងចំណីអាហារ   | គ្រូបង្រៀនភាសា   | វិស្វករឧស្សាហកម្ម និងផលិតកម្ម  | អ្នករចនាម៉ូត  | វិស្វករសំណង់ស៊ីវិល  |
| | អ្នកបង្កើតកម្មវិធី និងប្រព័ន្ធកុំព្យូទ័រ  | អ្នកបកប្រែ  | អ្នករចនាក្រាហ្វិច  | ស្ថាបត្យករ  | គ្រូបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មានវិទ្យា  |
| **អ្នកបច្ចេកទេស និងអ្នកជំនាញរង៖** ជាកម្រិតអ្នកបច្ចេកទេស និងអ្នកជំនាញរង ដែលទាមទារកម្រិតអប់រំចាប់ពីបរិញ្ញាបត្រឡើងទៅ និង | មន្ត្រីឥណទាន   | អ្នកមើលការខុសត្រូវការិយាល័យ  | អ្នករៀបចំកម្មវិធីប្រជុំ និងព្រឹត្តិការណ៍  | ភ្នាក់ងារប្រមូលទំនិញចេញ និងដឹកជញ្ជូន   | អ្នកបច្ចេកទេសគ្រឿងម៉ាស៊ីន  |

| | | | | | |
|---|---|---|---|---|---|
| មានបទពិសោធយ៉ាងតិច ១ឆ្នាំ | អ្នកមើលការខុសត្រូវក្នុងរោងចក្រ  | អ្នកបច្ចេកទេសគមនាគមន៍ និងព័ត៌មានវិទ្យា  | ជំនួយការគណនេយ្យករ  | អ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រ  | អ្នកតំណាងលក់  |
| **បុគ្គលិកគាំទ្រ និងលេខាធិការ៖** ជាកម្រិតផ្នែកបុគ្គលិកគាំទ្រ និងស្មៀន ដែលទាមទារកម្រិតអប់រំ បរិញ្ញាបត្ររងឡើងទៅ | បុគ្គលិកផ្នែកធនធានមនុស្ស  | បុគ្គលិកផ្នែកផលិតកម្ម  | បុគ្គលិកផ្នែកគណនេយ្យ និងបញ្ជី  | បុគ្គលិកខាងការរៀបចំការធ្វើដំណើរ  | បុគ្គលិកការិយាល័យទូទៅ  |
| **បុគ្គលិកផ្នែកលក់ និងសេវាកម្ម៖** ជាកម្រិតបុគ្គលិកបម្រើសេវាកម្ម ដែលទាមទារកម្រិតអប់រំចាប់ពីថ្នាក់ទី៩ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១(C1)ឡើងទៅ | បេឡាករ  | ជំនួយការគ្រូបង្រៀន  | អ្នកថែទាំក្មេង  | គ្រូបង្រៀនបើកបរ  | អ្នកពន្លត់អគ្គិភ័យ  |
| **កម្មករជំនាញសិប្បកម្ម និងការកែច្នៃដោយដៃ៖** ជាកម្រិតកម្មករ ឬសិប្បករ ដែលទាមទារកម្រិតអប់រំចាប់ពី ថ្នាក់ទី៩ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១(C1) ឡើងទៅ | អ្នកធ្វើស្បែកជើង  | អ្នកបាញ់ថ្នាំពណ៌  | ជាងផ្សារដែក *  | ជាងជួសជុលម៉ាស៊ីន *  | អ្នកដំឡើងអគ្គិសនី *  |
| | ជាងអេឡិចត្រូនិក *  | ជាងសំណង់ *  | អ្នកដុតនំ *  | ជាងកាត់ដេរសំលៀកបំពាក់ *  | អ្នកដំឡើងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា *  |
| **កម្មករខាងបញ្ជាម៉ាស៊ីន និង ដំឡើងគ្រឿងចក្រ៖** ជាកម្រិតកម្មករ ដែលទាមទារជំនាញវិជ្ជាជីវៈ | អ្នកបញ្ជាឡានស្ទូច  | អ្នកបញ្ជាម៉ាស៊ីនដេរ  | អ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់  | អ្នកបញ្ជាម៉ាស៊ីនធ្វើស្បែកជើង  | អ្នកដំឡើងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក  |

*កំណត់សម្គាល់៖ ជំនាញដែលមានក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (1.5M) ។

## ផ្នែកទី៤៖ ការចាប់យកឱកាសបណ្តុះបណ្តាល ប្រឹក្សាយោបល់ការងារ និងថែទាំសុខភាព

### ក. ឱកាសទទួលបានការបណ្តុះបណ្តាលដោយមិនគិតថ្លៃ និងទទួលបានប្រាក់ខែសមរម្យ



## ខ. ឱកាសទទួលបានការប្រឹក្សាយោបល់ និងឱកាសការងារ



## គ. ឱកាសទទួលបានការពិគ្រោះ និងថែទាំសុខភាព



# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

www.facebook.com/mlvt.gov.kh www.mlvt.gov.kh 1297/1286 t.me/molvtkhmer

អាសយដ្ឋាន៖ អគារលេខ ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
Address: Building 3, Russian Federation Blvd., Toek Laak I, Toul Kork, Phnom Penh